# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានស្ថិតិ និងពត៌មានទេសចរណ៍ នៃក្រសួងទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០២ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងទេសចរណ៍ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរចាំបាច់លើការងារ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សំរេច

មាត្រា ១.-

ត្រូវបានបង្កើតនាយកដ្ឋានស្ថិតិ និងពត៌មានទេសចរណ៍ចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍។

**មាត្រា ២.-**

នាយកដ្ឋាន ស្ថិតិ និងពត៌មានទេសចរណ៍ មានភារកិច្ច :

- សិក្សាស្រាវជ្រាវទិន្នន័យស្ថិតិទេសចរណ៍បរទេស និងទេសចរណ៍ក្នុងស្រុក
- គ្រប់គ្រងទិន្នន័យ សេវា និងឧស្សាហកម្មទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងផ្តល់រាល់ពត៌មានទេសចរណ៍
- ធ្វើការកែសំរួល និងឆ្លើយតបទាន់ពេលវេលានូវសំណួមពរពត៌មាននានា និងការផ្សព្វផ្សាយមិនប្រក្រតីស្តីអំពីវិស័យទេសចរណ៍
- គ្រប់គ្រងមជ្ឈមណ្ឌលពត៌មានទេសចរណ៍
- គ្រប់គ្រងការចែកចាយ និងផ្សព្វផ្សាយពត៌មានទេសចរណ៍ តាមបណ្តាញអ៊ិនធើណែត
- ធ្វើការចងក្រង បោះពុម្ព និងផ្សព្វផ្សាយពីទិន្នន័យ និងស្ថិតិទេសចរ ស្ថិតិបណ្តាសេវាកម្មទេសចរណ៍ ឯកសារស្តីពីសកម្មភាព ព្រឹត្តិការណ៍ និងពត៌មានផ្សេងៗដែលបំរើឱ្យវិស័យទេសចរណ៍
- អភិវឌ្ឍន៍ ផ្សព្វផ្សាយ និងថែរក្សាគេហទំព័ររបស់ក្រសួងទេសចរណ៍អោយទូលំទូលាយលើឆាកអន្តរជាតិ

**មាត្រា ៣.-**

នាយកដ្ឋានស្ថិតិ និងពត៌មានទេសចរណ៍ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប និងអមដោយអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ០៤ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ